ព្រឹត្តិបត្រព័ត៌មាន

# ការប្រែប្រួលអាកាសធាតុ

#៩

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
នាយកដ្ឋានប្រែប្រួលអាកាសធាតុ

មេសា-មិថុនា
២០១៧

## គោលនយោបាយប្រែប្រួលអាកាសធាតុ និងការអនុវត្ត

### យន្តការផ្តល់ឥណទានកាបូនរួមគ្នាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងប្រទេសកម្ពុជា

កម្ពុជាបានចូលរួមក្នុងយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ចាប់តាំងពីឆ្នាំ២០០៦ នៅពេលដែលគម្រោងយន្តការអភិវឌ្ឍន៍ស្អាត (CDM) ត្រូវបានអនុម័តលើកដំបូង។ ចាប់ពីពេលនោះមក គម្រោងCDMចំនួន១០ផ្សេងទៀត ក៏ត្រូវបានអនុម័តជាបន្តបន្ទាប់ ក៏ដូចជាគម្រោងREDD+ ចំនួនពីរ គម្រោងJCMចំនួនពីរ និងគម្រោងផ្សេងទៀតស្ថិតនៅក្នុងផែនការ។ ខណៈដែលCDM និង REDD+ ត្រូវបានអនុវត្តទៅតាមលក្ខខណ្ឌតម្រូវដែលកំណត់ដោយអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ(UNFCCC) JCM គឺជាប្រព័ន្ធមួយដែលបង្កើតឡើង ដើម្បីសហការជាមួយប្រទេសកំពុងអភិវឌ្ឍក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ហើយលទ្ធផលនៃការកាត់បន្ថយការបញ្ចេញឧស្ម័ននឹងត្រូវវាយតម្លៃដោយប្រទេសដៃគូ និងប្រទេសជប៉ុន។

JCMគឺជាយន្តការឥណទានកាបូនទ្វេភាគី ដែលត្រូវបង្កើតក្នុងគោលបំណងផ្តល់ភាពបត់បែនច្រើនក្នុងការឆ្លើយតបនឹងស្ថានភាពរបស់ប្រទេសកំពុងអភិវឌ្ឍ និងសម្រួលដល់ការផ្សព្វផ្សាយបច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធ និងសេវាកម្មកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។ កិច្ចព្រមព្រៀងភាពជាដៃគូបញ្ចេញកាបូនតិចរវាងប្រទេសជប៉ុននិងកម្ពុជា ក្នុងខែមេសា ឆ្នាំ២០១៤ គឺជាការចាប់ផ្តើមអនុវត្តសកម្មភាពJCMដំបូងក្នុងប្រទេសកម្ពុជាដោយមាននាយកដ្ឋានប្រែប្រួលអាកាសធាតុជា

*តទៅទំព័រទី១*




បច្ចេកទេសអំពូល LED បំភ្លឺផ្លូវប្រើការគ្រប់គ្រងដោយបណ្តាញគ្មានខ្សែ

## កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ

### យុទ្ធសាស្ត្រ និងផែនការសកម្មភាពបន្សាំ ដោះស្រាយបញ្ហាប្រឈមឆ្លងដែននៃតំបន់ទន្លេមេគង្គក្រោម

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើប្រទេសនៅតំបន់អាងទន្លេមេគង្គក្រោម រួមមានប្រទេសកម្ពុជា ឡាវ វៀតណាម និងថៃ គឺមានសភាពធ្ងន់ធ្ងរ ដោយសារសេដ្ឋកិច្ចរបស់ប្រទេសទាំងនេះពឹងផ្អែកខ្លាំងលើវិស័យដែលងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ដូចជាវិស័យកសិកម្ម និងនេសាទ។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុបង្កហានិភ័យដល់ជីវភាពប្រជាជនបើទោះជាមានកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ដោយប្រទេសនីមួយៗក៏ដោយ។

ការវិភាគរបស់ប្រទេសតំបន់អាងទន្លេមេគង្គក្រោមអំពីការឆ្លើយតបផ្នែកគោលនយោបាយទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើធនធានដែលពាក់ព័ន្ធនឹងទឹក បង្ហាញថាកិច្ចខិតខំប្រឹងប្រែងទាំងនោះមិនគ្រប់គ្រាន់ក្នុងការដោះស្រាយការប្រឈមទៅនឹងការប្រែប្រួលអាកាសធាតុឆ្លងដែនឡើយ។ ការវាយតម្លៃនេះបាននាំឱ្យគណៈកម្មការទន្លេមេគង្គ(MRC) និងប្រទេសសមាជិកទាំងបួន រៀបចំយុទ្ធសាស្ត្រសម្រាប់អាងទន្លេទាំងមូលគឺ "យុទ្ធសាស្ត្រ និងផែនការសកម្មភាពបន្សាំមេគង្គ (MASAP)"។

MASAP ផ្តោតសំខាន់លើបញ្ហាឆ្លងដែនសំខាន់

*តទៅទំព័រទី៣*

## មាតិកាព័ត៌មាន

គោលនយោបាយប្រែប្រួលអាកាសធាតុនិងការអនុវត្ត
- យន្តការឥណទានកាបូនរួមគ្នាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងប្រទេសកម្ពុជា .. ១
- ការវាយតម្លៃភាពងាយរងគ្រោះបណ្តាលមកពីការប្រែប្រួលអាកាសធាតុ៖ ពីការស្រាវជ្រាវបន្សាំឆ្ពោះទៅការអនុវត្ត ........................ ២
- ការរៀបចំថវិកាដែលឆ្លើយតបនឹងអាកាសធាតុជំរុញកំណើន GDP ក្នុងប្រទេសកម្ពុជា ..... ៣

កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ
- យុទ្ធសាស្ត្រនិងផែនការសកម្មភាពបន្សាំដោះស្រាយបញ្ហាប្រឈមឆ្លងដែននៃតំបន់ទន្លេមេគង្គក្រោម .. ១

សម្លេងពីមូលដ្ឋាន
- គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយខេត្តកសាងសមត្ថភាពទប់ទល់នឹងហានិភ័យអាកាសធាតុ ..... ៤
- ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវបង្កើនសមត្ថភាពប្រជាជនបន្សាំនឹងការប្រែប្រួលអាកាសធាតុ ....... ៥

ឯកសារបោះពុម្ពថ្មីៗ ................................ ៦
ការចេញផ្សាយបន្ទាប់ ................................ ៦
ឯកសារបោះពុម្ពផ្សាយនាពេលខាងមុខ ........... ៦
ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខ ............. ៦

## ចំណាប់អារម្មណ៍របស់និពន្ធនាយក

*សូមគោរពប្រិយមិត្តអ្នកអាន យើងខ្ញុំសូមស្វាគមន៍ចំពោះការអានព្រឹត្តិបត្រព័ត៌មានការប្រែប្រួលអាកាសធាតុ។ ព្រឹត្តិបត្រព័ត៌មាននេះចេញផ្សាយរៀងរាល់ត្រីមាស ដើម្បីឆ្លុះបញ្ចាំងអំពីការអភិវឌ្ឍគោលនយោបាយអាកាសធាតុថ្មីៗនៅកម្ពុជា ព្រមទាំងបច្ចុប្បន្នភាពការងារជាច្រើនដែលអនុវត្តក្រោមអាណត្តិនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ ដោយឡែកក្នុងត្រីមាសទី២និងទី៤នៃឆ្នាំនីមួយៗ យើងនឹងបន្ថែមការចែករំលែកបទពិសោធន៍សំខាន់ៗដែលអនុវត្តដោយអង្គការដៃគូនិងសហគមន៍នានាឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ យើងខ្ញុំសង្ឃឹមថាប្រិយមិត្តអ្នកអាននឹងផ្តល់ធាតុចូលដូចជាការផ្តល់មេរៀនល្អៗនិងករណីសិក្សានានាដែលនាំឱ្យព្រឹត្តិបត្រនេះជោគជ័យ៕*

## ក្រុមការងាររៀបចំ និងត្រួតពិនិត្យ

*ព្រឹត្តិបត្រព័ត៌មាននេះ ត្រូវបានរៀបចំកែសម្រួល និងផលិតដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយមានជំនួយបច្ចេកទេសពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា៕*

# គោលនយោបាយប្រែប្រួលអាកាសធាតុ និងការអនុវត្ត

## យន្តការផលធានការបូនរួមគ្នាកាត់បន្ថយការ ...

*តពីទំព័រទី១*

លេខាធិកាដ្ឋានរបស់JCMមានតួនាទីសំខាន់ក្នុងការភ្ជាប់ទំនាក់ទំនងរវាងស្ថាប័នរដ្ឋ ក្រុមហ៊ុនឯកជន និងដៃគូពាក់ព័ន្ធក្នុងការរៀបចំ និងអនុវត្តគម្រោងJCM។

គម្រោងដំឡើងបច្ចេកវិទ្យាបំភ្លឺផ្លូវដោយអំពូលLED គ្រប់គ្រងដោយប្រព័ន្ធគ្មានខ្សែ ដែលអនុម័តនៅឆ្នាំ២០១៦ គឺជាគម្រោងJCM ដំបូងគេក្នុងប្រទេសកម្ពុជា។ នៅពេលដែលអំពូលចំនួន ៩ ៧៧៥ ត្រូវបានបំពាក់រួចរាល់ គម្រោងនេះរំពឹងថានឹងអាចកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ប្រមាណ ៣ ៥០០ តោនសមមូលកាបូនកាបូនិករៀងរាល់ឆ្នាំ។ ការកាត់បន្ថយការប្រើប្រាស់អគ្គិសនីធ្វើឡើង តាមរយៈការប្រើប្រាស់ប្រព័ន្ធបំភ្លឺឆ្លាត និងអំពូលLEDដែលមានប្រសិទ្ធផលខ្ពស់ (ប្រសិទ្ធផលខ្ពស់ជាងអំពូលធម្មតា ប្រហែល៨០%)។ គម្រោងJCMទី២ គឺគម្រោងសន្សំសំចៃថាមពលក្នុងស្ថានីយប្រព្រឹត្តិកម្មទឹកស្អាត ក្នុងទីក្រុងភ្នំពេញដែលទើបអនុម័តក្នុងឆ្នាំនេះ និងគម្រោងប្រើប្រាស់ថាមពលអគ្គីសនីកកើតឡើងវិញពីរទៀតក្នុងផែនការ រួមមាន ការដំឡើងប្រព័ន្ធត្រជាក់ដោយប្រើថាមពលពន្លឺព្រះអាទិត្យកម្លាំង ១ម៉េហ្គាវ៉ាត់ ក្នុងផ្សារទំនើបអ៊ីអនកាំកូស៊ីជី និងម៉ាស៊ីនផលិតថាមពលដើរដោយថាមពលពន្លឺព្រះអាទិត្យកម្លាំង ០,៨ម៉េហ្គាវ៉ាត់ នៅសាលាអន្តរជាតិភ្នំពេញ។

គម្រោងទាំងនេះបង្ហាញពីបច្ចេកវិទ្យាមានប្រសិទ្ធផលថាមពលថ្មី អាចជួយកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ កាត់បន្ថយថ្លៃចំណាយ ព្រមទាំងរួមចំណែកដល់ការអនុវត្ត «ផែនការស្តីពីការចូលរួមចំណែករបស់កម្ពុជាក្នុងការអនុវត្តអនុសញ្ញាUNFCCC»។

## ការវាយតម្លៃភាពងាយរងគ្រោះបណ្តាលមកពីការប្រែប្រួលអាកាសធាតុ៖ ពីការស្រាវជ្រាវបន្សាំឆ្ពោះទៅការអនុវត្ត

នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងគណៈកម្មធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) កំពុងប្រើប្រាស់គោលការណ៍ណែនាំថ្នាក់ជាតិ សម្រាប់វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ (VRA) នៅថ្នាក់ក្រោមជាតិ។ លក្ខខណ្ឌតម្រូវនៃការរៀបចំVRA គឺជាផ្នែកមួយនៃប្រកាសអន្តរក្រសួងស្តីពីគោលការណ៍ណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការបង្កើតផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ និងកម្មវិធីវិនិយោគ ដែលអនុម័តដោយក្រសួងផែនការ និងក្រសួងមហាផ្ទៃ ក្នុងខែមីនា ឆ្នាំ២០១៧។ ជាលទ្ធផល VRA អាចប្រើប្រាស់ ដើម្បីបញ្ជ្រាបបន្សាំ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ និងកម្មវិធីវិនិយោគឃុំ។

ប្រកាសនេះ ក៏បានបញ្ចូលនូវគោលការណ៍ណែនាំបច្ចេកទេសអំពីរបៀបនៃការចូលរួមរបស់សហគមន៍ក្នុងការវាយតម្លៃភាពងាយរងគ្រោះថាតើការប្រែប្រួលអាកាសធាតុបានជះឥទ្ធិពលយ៉ាងណាខ្លះទៅលើសហគមន៍មូលដ្ឋាន តាមរយៈការត្រួតពិនិត្យមុខសញ្ញាគ្រោះថ្នាក់ភាពប្រឈមភាពរួសនិងសមត្ថភាពបន្សាំដើម្បីកាត់បន្ថយហានិភ័យឱ្យនៅកម្រិតអប្បរមា។ ទោះជាយ៉ាងនេះក៏ដោយVRAនៅមានចំណុចខ្វះខាត។ ចំណុចខ្វះខាតចម្បងនៃការប្រើប្រាស់VRA គឺការមិនបានរួមបញ្ចូលទិន្នន័យអាកាសធាតុបង្រួញមាត្រដ្ឋានក្នុងការកំណត់វិធានការបន្សាំនៅមូលដ្ឋាន។ ជំហានបន្ទាប់ក្នុងការកែលម្អលទ្ធផលVRA គឺត្រូវប្រើទិន្នន័យអាកាសធាតុបង្រួម និងព័ត៌មានព្យាករណ៍អាកាសធាតុ ក៏ដូចជាការបង្កើតគោលការ ណ៍ ថ្មីៗដើម្បីបញ្ចៀសសកម្មភាពបន្សាំមិនត្រឹមត្រូវ ក្នុងការកំណត់អាទិភាពគម្រោង។

ភាពងាយរងគ្រោះនៃប្រព័ន្ធមួយ (សហគមន៍ បរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធ...) ចំពោះការប្រែប្រួលអាកាសធាតុត្រូវបានវាយតម្លៃក្នុងបរិបទភាពប្រឈម ភាពរួស និងសមត្ថភាពបន្សាំនឹងព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ ដូចបង្ហាញក្នុងរូបភាពខាងក្រោម។ ភាពប្រឈម (exposure) ទៅនឹងការប្រែប្រួលអាកាសធាតុ សំដៅលើកម្រិតដែលប្រព័ន្ធមួយប្រឈមមុខខ្លាំងទៅនឹងវិសមរូបអាកាសធាតុ។ ភាពប្រឈមចំពោះការប្រែប្រួលអាកាសធាតុរបស់សហគមន៍មួយ សំដៅលើវត្តមាននៃសហគមន៍នោះ (រួមទាំងប្រជាជន ជីវភាព ហេដ្ឋារចនាសម្ព័ន្ធ បរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌) នៅទីតាំងមួយ ដែលអាចទទួលរងឥទ្ធិពលអវិជ្ជមានខ្លាំងពីវិសមរូបអាកាសធាតុ។ ភាពរួស (sensitivity) គឺជាកម្រិតដែលប្រព័ន្ធមួយទទួលរងផលអវិជ្ជមាន ឬផលចំណេញ ពីគ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុ។ មុខសញ្ញាគ្រោះថ្នាក់ (hazard) ជាទូទៅសំដៅលើផលប៉ះពាល់ជារូបវន្តទាក់ទងនឹងអាកាសធាតុ ដែលអាចបង្កឱ្យបាត់បង់ជីវិត ឬគ្រោះថ្នាក់ដល់សុខភាព ហេដ្ឋារចនាសម្ព័ន្ធ ជីវភាពរស់នៅ និងធនធានបរិស្ថាន។ សមត្ថភាពបន្សាំ (adaptive capacity) គឺជាសមត្ថភាពដែលប្រព័ន្ធមួយអាចឆ្លើយតបទៅនឹងហានិភ័យអាកាសធាតុ។ ឧទាហរណ៍៖ សហគមន៍ដែលមានសមត្ថភាពបន្សាំខ្ពស់ គឺជាសហគមន៍ដែលមានការត្រៀមខ្លួនបានល្អ និងមានវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (សហគមន៍ដែលពឹងពាក់តិចតួចទៅលើវិស័យឬជីវភាពដែលមានភាពរួសនឹងអាកាសធាតុឬសហគមន៍ដែលមានហេដ្ឋារចនាសម្ព័ន្ធធន់នឹងអាកាសធាតុ និងមានបច្ចេកវិទ្យាបន្សាំ)។




*ក្របខណ្ឌទស្សនទាននៃការវាយតម្លៃភាពងាយរងគ្រោះ*



*កិច្ចប្រជុំបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ និងកម្មវិធីវិនិយោគឃុំ ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧ នៅខេត្តកោះកុង*

**ឧបករណ៍VRA**

1. ការបង្កើតផែនទីមុខសញ្ញាគ្រោះថ្នាក់ ដើម្បីកំណត់ភាពងាយរងគ្រោះនៅមូលដ្ឋាន និងផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធក្នុងតំបន់។
2. ការវិភាគនិន្នាការប្រវត្តិនៃមុខសញ្ញាគ្រោះថ្នាក់ពាក់ព័ន្ធនឹងអាកាសធាតុ ដើម្បីស្វែងយល់ពីកម្រិតនៃភាពប្រឈម និងភាពរួសទៅនឹងព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ ដោយពិចារណាលើភាពញឹកញាប់ អាំងតង់ស៊ីតេ និងផលប៉ះពាល់ចំពោះក្រុមងាយរងគ្រោះ ដោយរួមបញ្ចូលទាំងស្ត្រី និងជនក្រីក្រ។
3. ការវិភាគទម្រង់អក្សរ H (H form analysis) គឺជាឧបករណ៍វាយតម្លៃដោយមានការចូលរួម ដើម្បីប្រមូលផ្តុំការវិភាគនិន្នាការ តាមរយៈការពិនិត្យមើលព្រឹត្តិការណ៍ធ្ងន់ធ្ងរសំខាន់ៗ និងផលប៉ះពាល់ជាក់លាក់នៅមូលដ្ឋាន។ ឧបករណ៍នេះក៏ជួយក្នុងការកៀរគរធនធានដែលមាននៅមូលដ្ឋាន និងបង្កើតវិធានការបន្សាំពេញលេញ។
4. ការធ្វើចំណាត់ថ្នាក់គម្រោងបន្សាំដែលបានស្នើឡើង ដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់ក្រុមគោលដៅ។ ឧបករណ៍នេះជួយកំណត់អាទិភាពជម្រើសបបន្សាំ និងកៀរគរការគាំទ្រពីដៃគូដែលមានសក្តានុពល។

## ការរៀបចំថវិកាដែលឆ្លើយតបនឹងអាកាសធាតុ ជំរុញកំណើន GDP ក្នុងប្រទេសកម្ពុជា

ប្រទេសកម្ពុជាត្រូវបានចាត់ជាប្រទេសមួយក្នុងចំណោម១០ប្រទេស ដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុ។ ១៧%នៃឃុំសរុប ត្រូវបានចាត់ទុកថានឹងមានភាពងាយរងគ្រោះខ្ពស់ ហើយ៣២% មានភាពងាយរងគ្រោះមធ្យមចំពោះការប្រែប្រួលអាកាសធាតុ (NCSD, ២០១៤)។ ការបាត់បង់ដោយសារការប្រែប្រួលអាកាសធាតុ អាចកាត់បន្ថយកំណើន GDPប្រមាណ១,៥% ត្រឹមឆ្នាំ២០៣០ និងប្រមាណ៣,៥% ត្រឹមឆ្នាំ ២០៥០។ ប្រសិនបើគ្មានវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ កំណើនGDP អាចកើនត្រឹមតែ១% ក្នុងមួយឆ្នាំប៉ុណ្ណោះត្រឹមឆ្នាំ២០៥០ (CCFF, ២០១៤)។

ចាប់តាំងពីឆ្នាំ២០១៥ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) បាននិងកំពុងធ្វើការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ក្រសួងធនធានទឹកនិងឧតុនិយម (MoWRAM) ក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT) និងក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ដើម្បីធ្វើសមាហរណកម្មការប្រែប្រួលអាកាសធាតុ ទៅក្នុងដំណើរការរៀបចំផែនការ និងថវិកា។ GIZ ក៏បានផ្ដល់ការគាំទ្រស្រដៀងនេះដល់ក្រសួងបរិស្ថាន និងក្រសួងសុខាភិបាលដែរ។ ការវិភាគថ្លៃដើម- ផលប្រយោជន៍នៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ បង្ហាញថាការរៀបចំថវិកា និងផែនការឆ្លាតខាងអាកាសធាតុ នឹងផ្ដល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ច និងកំណើនGDP ។ ក្រាហ្វិចខាងលើបង្ហាញពីការរៀបគម្រោងស្នើសុំថវិការបស់MPWTទៅកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឆ្នាំសារពើពន្ធ២០១៧ ដោយមាន និងដោយគ្មានការបញ្ចូលការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។




*និន្នាការប្រែប្រួលអាកាសធាតុសម្រាប់អត្ថប្រយោជន៍នៃការវិភាគសាកល្បង*

ការវិភាគសម្រាប់គម្រោងស្តារផ្លូវលេខ៣៨២A ក្នុងខេត្តព្រៃវែង ដោយកែប្រែពីផ្លូវកាលួសក្រួសទៅជាផ្លូវកៅស៊ូពីរជាន់ (DBST) បណ្ដោយ ១,២ គីឡូម៉ែត្រ និងទទឹង ៦ម៉ែត្រ បានបង្ហាញថា៖

*តទៅទំព័រទី៤*

## កិច្ចចរចារអន្តរជាតិស្តីពីអាកាសធាតុ

### យុទ្ធសាស្ត្រ និងផែនការសកម្មភាពបន្សុំ ដោះស្រាយ ...

*តពីទំព័រទី១*

រួមមាន ការប្រឈមបង្កដោយកំណើនតម្រូវការថាមពល និងតម្រូវការទឹកក្នុងប្រទេសទន្លេមេគង្គក្រោម (LMB) ទាំងបួនដែលកំពុងប្រឈមបញ្ហាខ្វះខាតទឹកតាមរដូវកាលជាប្រចាំ។ លើសពីនេះ ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ប្រទេសLMB ជានិច្ចកាលបានបញ្ចូលការវិនិយោគយ៉ាងច្រើនទៅលើការសង់សង់ទំនប់វារីអគ្គិសនី និងទំនប់ធារាសាស្ត្រនៅតាមដងទន្លេមេ និងតាមដៃទន្លេមេគង្គ ទៅក្នុងផ្នែកមួយនៃវិធានការអាទិភាព សម្រាប់កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ សកម្មភាពទាំងនេះអាចធ្វើឱ្យផ្លាស់ប្ដូររបបទឹកក្នុងតំបន់ទន្លេមេគង្គ ដែលជាលទ្ធផលអាចបង្កឱ្យមានការកើនឡើងនូវការគំរាមគំហែងដល់សន្តិសុខស្បៀងជាតិ និងភាពរេចរឹលនៃធនធានធម្មជាតិនិងបរិស្ថាន ជាពិសេសប្រទេសនៅខាងក្រោមទំនប់វារីអគ្គិសនី។

នៅពេលដែលMASAPត្រូវបានអនុម័ត យុទ្ធសាស្ត្រនេះនឹងផ្ដល់នូវគោលការណ៍ណែនាំ និងគាំទ្រដល់ប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គលើបញ្ហាសំខាន់ៗ ដូចជា៖

១. តម្រូវការដោះស្រាយបញ្ហាទាក់ទងនឹងអាកាសធាតុ និង ទឹកនៅកម្រិតតំបន់អាងទន្លេ ដោយប្រើប្រាស់វិធីសាស្ត្រគ្រប់គ្រងទឹកបែបសមាហរណកម្ម។
២. តម្រូវការដោះស្រាយបញ្ហាឆ្លងដែនពាក់ព័ន្ធបន្សាំនឹងការប្រែប្រួលអាកាសធាតុ និង
៣. តម្រូវការគាំទ្រប្រទេសតាមដងទន្លេក្នុងការអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពបន្សាំរបស់ខ្លួននៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ។

MASAP ក៏បានបញ្ចូលនូវកម្រងទស្សនទានសម្រាប់គម្រោងបន្សាំឆ្លងដែន ដោយផ្ដោតទៅលើយុទ្ធសាស្ត្រអាទិភាពចំនួនប្រាំពីរ៖

១. បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ កម្មវិធី និងផែនការថ្នាក់ជាតិ និងថ្នាក់តំបន់
២. កិច្ចសហការ និងភាពជាដៃគូក្នុងតំបន់ និងអន្តរជាតិលើការបន្សាំ




*សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់លើកទីបីក្នុងប្រទេសកម្ពុជា ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅខេត្តសៀមរាប*

៣. អនុវត្តន៍ជម្រើសបន្សាំដែលមានភាពរួសផ្នែកយេនឌ័រ និងឆ្លងដែន
៤. លទ្ធភាពទទួលបានហិរញ្ញវត្ថុលើកម្មវិធីបន្សាំ
៥. ការត្រួតពិនិត្យ ការប្រមូលទិន្នន័យ និងការចែកចាយ
៦. ការអភិវឌ្ឍសមត្ថភាពសម្រាប់ការធ្វើផែនការ និងយុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុ
៧. ការផ្សព្វផ្សាយឯកសាររបស់MRC ស្ដីពីការប្រែប្រួលអាកាសធាតុ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

ការរៀបចំMASAP បានចាប់ផ្ដើមនៅក្នុងកិច្ចប្រជុំឆ្នាំ២០១៤ និងមានការប្រឹក្សាយោបល់ជាបន្តបន្ទាប់។ ការប្រឹក្សាយោបល់ថ្មីៗ ត្រូវបានប្រារព្ធឡើងក្នុងប្រទេសឡាវ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ ក្នុងវេទិកាអ្នកពាក់ព័ន្ធថ្នាក់តំបន់ដែលសង្គមស៊ីវិល អង្គការជាតិនិងអន្តរជាតិ និងដៃគូពាក់ព័ន្ធក្នុងតំបន់និងអន្តរជាតិ អាចផ្ដល់យោបល់លើសេចក្ដីព្រាងនេះ។ យុទ្ធសាស្ត្រនេះគឺជាឱកាសដ៏កម្រសម្រាប់បំពេញចន្លោះប្រហោងនៃយុទ្ធសាស្ត្រ និងផែនការប្រែប្រួលអាកាសធាតុជាតិដែលមានស្រាប់របស់ប្រទេសទន្លេមេគង្គក្រោមទាំងបួន និងរបាយការណ៍ចូលរួមចំណែករបស់កម្ពុជាក្នុងការអនុវត្តអនុសញ្ញាUNFCCC ជាពិសេសទៅលើបន្សាំ។ សេចក្ដីព្រាងចុងក្រោយMASAP រំពឹងថានឹងពិភាក្សា និងអនុម័តដោយគណៈកម្មការរួមគណៈកម្មការទន្លេមេគង្គក្នុងឆ្នាំ២០១៧។

# គោលនយោបាយប្រែប្រួលអាកាសធាតុ និងការអនុវត្ត

## ការរៀបចំថវិកាដែលឆ្លើយតបនឹងអាកាសធាតុ ជំរុញ ...

*តពីទំព័រទី៣*

- គួរមានការកែតម្រូវការវិនិយោគ ដោយគិតគូរពីការប្រែប្រួលអាកាសធាតុ។ ការវិភាគបង្ហាញថា អនុបាតថ្លៃដើម-ផលប្រយោជន៍សម្រាប់គម្រោងធម្មតាធ្លាក់ចុះពី ២,២២ មក ១,៦៣ នៅពេលការប្រែប្រួលអាកាសធាតុកើតឡើង។ ប៉ុន្តែ អនុបាតសម្រាប់គម្រោងធន់នឹងអាកាសធាតុ អាចរក្សាតម្លៃដដែល២,១៦ ជាករណីរឹងមាំសម្រាប់រៀបចំគម្រោងស្ពានដែលគិតគូរពីការប្រែប្រួលអាកាសធាតុ។
- អត្ថប្រយោជន៍នៃការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុ គឺអាចបញ្ចៀសការខូចខាតដែលបណ្តាលមកពីអាកាសធាតុ និងថ្លៃចំណាយពាក់ព័ន្ធនឹងការជួសជុលបន្ទាន់ និងការថែទាំ។
- អត្ថប្រយោជន៍នៃគម្រោងសាងសង់ស្ពានធន់នឹងអាកាសធាតុ(បន្ទាត់លឿងក្នុងក្រាហ្វិច) គឺមានតិចតួច។

រាជរដ្ឋាភិបាលកម្ពុជា បានដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៨-២០២០ និងសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨។ ក្រសួងពាក់ព័ន្ធអាចប្រើប្រាស់ការវិភាគថ្លៃដើម-ផលប្រយោជន៍ ដើម្បីបង្ហាញនូវកំណើនអត្ថប្រយោជន៍នៃហេដ្ឋារចនាសម្ព័ន្ធធន់នឹងអាកាសធាតុ និងបញ្ជាក់ពីភាពត្រឹមត្រូវនៃការចំណាយខ្ពស់ទៅលើការវិនិយោគដំបូង។ សម្រាប់ថវិកាបច្ចុប្បន្ន ក្រសួងពាក់ព័ន្ធគួរតែពិនិត្យលើសកម្មភាពមួយចំនួន ដើម្បីបញ្ជាក់ថាសកម្មភាពនោះពាក់ព័ន្ធនឹងអាកាសធាតុ ហើយស្នើសុំធនធានបន្ថែម។ ទំនាក់ទំនងជាបន្តរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធគឺជាតម្រូវការចាំបាច់ដើម្បីឱ្យប្រាកដថាផលចំណេញផ្នែកសេដ្ឋកិច្ចដែលបានមកពីការរៀបចំថវិកាឆ្លើយតបនឹងអាកាសធាតុ។



*កិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងផែនការកម្មវិធីវិនិយោគរបស់ក្រសួង ឆ្នាំ២០១៨ ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ នៅក្រសួងសាធារណការ និងដឹកជញ្ជូន*

# សម្លេងពីមូលដ្ឋាន

## គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយខេត្តកសាងសមត្ថភាពទប់ទល់នឹងហានិភ័យអាកាសធាតុ

ខេត្តកែប ជាខេត្តជាប់ឈូងសមុទ្រនៅភាគខាងត្បូងនៃប្រទេសកម្ពុជា។ ភាពប្រឈមនឹងហានិភ័យអាកាសធាតុ កំពុងបង្កក្តីបារម្ភកាន់តែធ្ងន់ធ្ងរដោយសារព្រឹត្តិការណ៍ធាតុអាកាសកើនឡើងកាន់តែញឹកញាប់ និងធ្ងន់ធ្ងរដូចជាខ្យល់ព្យុះនិងគ្រោះរាំងស្ងួត រួមនឹងការហូរចូលនៃទឹកប្រៃ។ គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត (PCDM) នៅគ្រប់លំដាប់ថ្នាក់ (ខេត្ត ស្រុក និងឃុំ) និងមន្ទីរពាក់ព័ន្ធនានាក្នុងខេត្តបាន និងកំពុងពង្រឹងសមត្ថភាពរបស់ខ្លួនដោះស្រាយហានិភ័យអាកាសធាតុ។ លោកស្រី កែវ នី អនុប្រធានមន្ទីរកិច្ចការនារីខេត្ត និងសមាជិកផ្សេងទៀតរបស់ PCDMខេត្តកែប បានកំពុងធ្វើការរួមគ្នាក្នុងការឆ្លើយតបនឹងហានិភ័យអាកាសធាតុ។ ទោះបីជា លោកស្រី កែវ នី ទើបតែធ្វើការក្នុងផ្នែកនេះ និងទើបទទួលបានការបណ្តុះបណ្តាលផ្នែកប្រែប្រួលអាកាសធាតុក្នុងឆ្នាំ២០១៦ គាត់តែងតែចូលរួមក្នុងកម្មវិធីកសាងសមត្ថភាព និងសកម្មភាពឃុំ។ គាត់បានចូលរួមវគ្គបណ្តុះបណ្តាលជាមួយមន្ត្រីថ្នាក់ខេត្តទទួលបន្ទុកគ្រោះមហន្តរាយ និងក្រុមប្រឹក្សាឃុំដទៃទៀត អំពីរបៀបផ្សព្វផ្សាយព័ត៌មានប្រកាសអាសន្នដោយប្រើប្រាស់ម៉េក្រូ។ បន្ទាប់មក ពួកគាត់បានពង្រីកវិធីសាស្ត្រផ្តល់ដំណឹងជាមុននេះ តាមរយៈវិទ្យុ និងទូរស័ព្ទចល័ត។ ការបណ្តុះបណ្តាលផ្នែកបរិស្ថានដែលរួមបញ្ចូលទាំងការប្រែប្រួលអាកាសធាតុ បានជួយឱ្យគាត់បានយល់ដឹងកាន់តែច្បាស់ពីការប្រែប្រួលអាកាសធាតុ ដូចជាមូលហេតុ និងផលប៉ះពាល់បន្សាំ និងវិធានការកាត់បន្ថយដែលអាចឆ្លើយតបនឹងបញ្ហានេះ។



*លោកស្រី កែវ នី តំណាងស្រុកដំណាក់ចង្អើរ និងមេឃុំពងទឹក (ពីស្តាំទៅឆ្វេង) ផ្តល់មតិនានាក្នុងការបង្កើនសមត្ថភាពដោះស្រាយហានិភ័យអាកាសធាតុ*

លោកស្រីយល់ថា ប្រព័ន្ធផ្តល់ព័ត៌មានជាមុន គឺជាឧបករណ៍ដ៏សំខាន់ក្នុងការបង្កើត និងផ្សព្វផ្សាយព័ត៌មានគ្រោះមហន្តរាយអាកាសធាតុបានទាន់ពេលវេលា។ ប្រព័ន្ធនេះអាចជួយភ្នាក់ងារឃុំរៀបចំ និងធ្វើសកម្មភាពត្រឹមត្រូវ និងទាន់ពេលវេលា ដើម្បីកាត់បន្ថយភាពអាចកើតមានឡើងនៃគ្រោះថ្នាក់និងការខូចខាតផ្សេងៗ។ ប៉ុន្តែប្រព័ន្ធនេះនៅមិនទាន់មាននៅក្នុងខេត្តកែបនៅឡើយទេ។ ហេតុនេះ មន្ត្រីថ្នាក់ខេត្តបានព្យាយាមដោះស្រាយបញ្ហាហានិភ័យអាកាសធាតុតាមស្ថានភាពជាក់ស្តែង។ ឧទាហរណ៍ ពួកគេបានសហការជាមួយមន្ទីរពាក់ព័ន្ធធ្វើការសាងសង់ទំនប់តាមបណ្តោយឆ្នេរសមុទ្រ ដើម្បីកាត់បន្ថយការជ្រាបចូលនៃទឹកសមុទ្រ។



*ទំនប់បណ្តោយឆ្នេរសមុទ្រដើម្បីការពារការហូរចូលនៃទឹកសមុទ្រ*

បន្ថែមពីនេះ មន្ទីរកសិកម្មខេត្តបានពង្រឹងសមត្ថភាពបន្សាំរបស់ប្រជាជនទៅនឹងការប្រែប្រួលអាកាសធាតុតាមរយៈការផ្តល់ចំណេះដឹងមូលដ្ឋានចែកចាយពូជស្រូវដែលមានភាពធន់ និងការបណ្តុះបណ្តាលចំណេះដឹងផ្នែកចិញ្ចឹមសត្វ។ មន្ត្រីស្រុកក៏បានអប់រំប្រជាជនអំពីការគ្រប់គ្រងទឹក និងអនាម័យតាមរយៈកិច្ចប្រជុំជាក្រុមតូចៗ។

តាមគំនិតលោកស្រី កែវ នី ចំណេះដឹងដែលទទួលបានមិនទាន់គ្រប់គ្រាន់នៅឡើយទេ ដោយសារវគ្គបណ្តុះបណ្តាលមានរយៈពេលខ្លី និងមិនមានឯកសារគ្រប់គ្រាន់។ អ្នកស្រីបានលើកឡើង នូវអនុសាសន៍មួយចំនួនដូចខាងក្រោម សម្រាប់ពង្រឹងការរៀបចំ និងការយល់ដឹងនៅសហគមន៍ ៖

- រៀប ចំ វគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីការប្រែប្រួលអាកាសធាតុដែលស៊ីគ្នានឹងបរិបទមូលដ្ឋាន
- ផលិតឯកសារបណ្តុះបណ្តាល ដែលផ្តោតសំខាន់លើការប្រែប្រួលអាកាសធាតុ និងផ្តល់នូវអន្តរាគមន៍ដែលអាចអនុវត្តបាន ។
- ជៀសវាងការបណ្តុះបណ្តាលតែរយៈពេលមួយថ្ងៃ។
- ផ្តល់ការគាំទ្រ ដល់ការដំឡើងប្រព័ន្ធផ្តល់ព័ត៌មានជាមុននៅក្នុងខេត្ត
- ផលិតប័ណ្ណព័ត៌មាន ស្តីពី ការបន្សាំ និងវិធានការកាត់បន្ថយ ដើម្បីបិទផ្សាយនៅតាមសង្កាត់។

## ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវបង្កើនសមត្ថភាពប្រជាជនបន្សាំនឹងការប្រែប្រួលអាកាសធាតុ

លោកស្រីញ៉ែម ភា អាយុ៤៨ឆ្នាំ ជាកសិកររស់នៅក្នុងភូមិបុសលាវក្រោម ខេត្តក្រចេះ បានបង្ហាញយើងពីរបៀបបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដោយប្រើប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ (SRI)។ សព្វថ្ងៃគាត់រស់នៅក្នុងផ្ទះតូចសង់ពីឈើ ហើយគាត់មានដីពីរកន្លែង (៦អា) សម្រាប់ដាំដុះស្រូវ និងបន្លែផ្សេងៗ។ រហូតមកដល់ពេលថ្មីៗនេះ ទិន្នផលដំណាំរបស់គាត់មិនដែលបានផលខ្ពស់នោះទេ ដោយសារតែកង្វះខាតចំណេះដឹងបច្ចេកទេសក្នុងការដាំដុះឱ្យបានល្អ។ ក្រៅពីនេះ ការប្រែប្រួលអាកាសធាតុ បានធ្វើឱ្យភ្លៀងធ្លាក់មិនទៀងទាត់ ហើយគ្រោះរាំងស្ងួត និងទឹកជំនន់ ដែលបានធ្វើឱ្យខូចខាតដល់គ្រាប់ពូជ ដំណាំ ក៏ដូចជាបង្កឱ្យមានការកើនឡើង ចំនួនសត្វល្អិត។

ដោយសង្កេតឃើញបញ្ហានេះ អ្នកស្រី ញ៉ែម ភា បានសំរេចចិត្តផ្លាស់ប្តូរវិធីសាស្ត្រធ្វើកសិកម្មក្នុងឆ្នាំ២០១៦ ដោយប្រើប្រាស់ប្រព័ន្ធប្រពលវប្បកម្មស្រូវទៅលើដីរបស់គាត់មួយកន្លែង ក្រោមការគាំទ្រពីគម្រោង "បង្កើនផលិតកម្មស្រូវក្នុងខេត្តក្រចេះ" របស់អង្គការសង្គ្រោះសត្វព្រៃកម្ពុជា។ ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវគឺជាបណ្តុំបច្ចេកទេសកសិកម្ម ដែលអាចជួយកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងបង្កើនផលិតកម្មស្រូវ។ អ្នកស្រី ញ៉ែម ភា និងអ្នកភូមិ បានប្រើប្រាស់វិធានប្រាំនៃប្រពលវប្បកម្មដំណាំស្រូវ ស្របតាមដំណាក់លូតលាស់របស់ស្រូវ៖

ដំណាក់កាលទី១៖ ការជ្រើសរើសពូជស្រូវ
ដំណាក់កាលទី២៖ ការរៀបចំដី និងសាបព្រួស
ដំណាក់កាលទី៣៖ ការដកស្ទូង
ដំណាក់កាលទី៤៖ ការថែទាំ
ដំណាក់កាលទី៥៖ ការច្រូតកាត់ និងស្តុកទុក

ក្រោយពីបានអនុវត្តបច្ចេកទេសនេះអស់ពេលមួយរយៈ គាត់សង្កេតឃើញថាបរិមាណ ពូជស្រូវដែលត្រូវប្រើតិចជាងមុន ដោយសារតែគ្រាប់


ដំណាំស្រូវបែបប្រពលវប្បកម្មដែលមានអាយុ១៥ថ្ងៃ របស់លោកស្រី ញ៉ែម ភា

ពូជ ១ដើម អាចបំបែកកូនបានយ៉ាងតិច ២០ទៅ ៣០ដើម ហើយដើមដុះវែងជាងមុន។ គាត់ក៏បានកត់សំគាល់ផងដែរថា គាត់អាចបង្កើនផលិតកម្មស្រូវដោយការធ្វើស្រូវនៅដើមរដូវវស្សា មុនពេលទឹកជំនន់ចូលមកដល់។ ទិន្នផលស្រូវរបស់គាត់បានកើនឡើងដល់ ៣០២គក ដែលកាលពឆ្នាំមុនគាត់ទទួលបានតែ ១០៦គកប៉ុណ្ណោះ។ លោកស្រីក៏បានបញ្ជាក់ថា គាត់មិនដែលចូលរួមក្នុងគម្រោងពីមុនៗទេ ហើយក៏មិនដែលយកចិត្តទុកដាក់លើការជ្រើសរើសពូជស្រូវនិងការថែទាំពូជដែរ គាត់តែងតែប្រើប្រាស់ពូជច្រើនប្រភេទ។ តែឥឡូវនេះ គាត់ប្រើប្រាស់ពូជតិចជាងមុន ហើយគ្រួសារមានប្រាក់កម្រៃច្រើនជាងមុនសម្រាប់ទិញអាហារ សន្សំ និងចំណាយផ្សេងៗក្នុងគ្រួសារ។ *(អត្ថបទដោយ៖ អង្គការសង្គ្រោះសត្វព្រៃ តាមរយៈវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា)*។


*លោកស្រី ញ៉ែម ភា បង្ហាញពីការធ្វើស្រែបង្ហាញរបស់គាត់*

**វិធីសាស្ត្រប្រព័ន្ធប្រពលវប្បកម្មស្រូវ**

SRI មានគោលបំណងបង្កើតលក្ខខ័ណ្ឌល្អប្រសើរដល់ការលូតលាស់ឬស និងដើមស្រូវ។ នៅពេលឬសដុះល្អ គ្រាប់ស្រូវនឹងកើនឡើងកាន់តែច្រើន។ គំនិត និងគោលការណ៍មូលដ្ឋានសំខាន់របស់SRI មាន៖

- ដាំសន្ទូងល្អ រឹងមាំ គឺត្រូវដាំពីសំណាបដែលដុះពីពូជល្អ និងថ្លោសដែលត្រូវបានសាបព្រួសនៅលើថ្នាល ស្រដៀងនឹងការដាំបន្លែ ដែលត្រូវការស្រោចទឹកដោយដៃ។
- ចន្លោះ រវាងសន្ទូងនីមួយៗមានគន្លាតធំ ហើយល្អបំផុតគឺបាន សំណាបមួយដើមក្នុងមួយគុម្ព។ ចន្លោះពីគុម្ពមួយទៅគុម្ពមួយទៀតកាន់តែធំ ហើយស្មើគ្នា ដើម្បីជៀសវាងការដុះទើសគ្នានៅពេលឬសនិងមែក លូតលាស់កាន់តែច្រើន
- ស្ទូងល្មមៗ ហើយរាក់ (ប្រហែល១ទៅ២សង់ទីម៉ែត្រ) ដើម្បីធានាថាឬសដុះលូតលាស់លឿន
- ស្ថានភាពដីត្រូវមានខ្យល់ដកដង្ហើមគ្រប់គ្រាន់៖ ត្រូវជៀសវាងស្រោចទឹក ហើយទុកទឹកឱ្យដក់ជាប្រចាំ
- ដកស្មៅជាប្រចាំ ដើម្បីទប់ស្កាត់ការដុះប្រជែងជាមួយស្រូវ។ ល្អបំផុតគឺប្រើម៉ាស៊ីនដកស្មៅរុញដោយដៃ ព្រោះវាជួយដល់ការលូតលាស់របស់ឬស និងសារពាង្គកាយមានប្រយោជន៍ក្នុងដី។
- បង្កើនសារធាតុសរីរាង្គដោយការប្រើដីកំប៉ុស្ត៍ ដែលអាចជួយបង្កើនសកម្មភាពជីវសាស្ត្រក្នុងដី។

(ប្រភព: CEDAC ២០១២)

# ឯកសារបោះពុម្ពថ្មីៗ




សទ្ទានុក្រមការប្រែប្រួលអាកាសធាតុ
www.camclimate.org.kh/en/lexicon.html




App របស់សទ្ទានុក្រមការប្រែប្រួលអាកាសធាតុ
- Andriod: CCLexcicon
- iOS: CCLexicon




របាយការណ៍ពិនិត្យចំណាយជាសាធារណៈលើអាកាសធាតុ ២០១៥
www.camclimate.org.kh/en/documents-and-media/library/category/39-financing.html?

# ការចេញផ្សាយបន្ទាប់...

## រដ្ឋាភិបាល និងដៃគូរអភិវឌ្ឍន៍ពិភាក្សាអំពីការបង្កើតយន្តការសម្របសម្រួលឆ្លើយតបការប្រែប្រួលអាកាសធាតុ



ការប្រែប្រួលអាកាសធាតុគឺជាបញ្ហាអន្តរវិស័យ មិនស្ថិតនៅដាច់ដោយឡែកនោះទេ។ កម្មវិធីប្រែប្រួលអាកាសធាតុតែឯកឯងមិនគួរបង្កើតឡើយនៅប្រទេសកម្ពុជា ដោយសារវិធានការឆ្លើយតបនោះ មិនមានប្រសិទ្ធភាពឡើយ។ មធ្យោបាយតែមួយដែលអាចសម្រេចបាននូវលទ្ធផល គឺការបញ្ចូលសកម្មភាពប្រែប្រួលអាកាសធាតុទៅក្នុងការងារប្រចាំថ្ងៃ មានជាអាទិ៍ ទៅក្នុងផែនការយុទ្ធសាស្ត្រ និងផែនការដំណើរការនៃការគ្រប់គ្រងថវិកា សមស្របទៅនឹងអាទិភាពជាតិ ហើយមានការសម្របសម្រួលគ្នាដ៏ប្រសើររវាងដៃគូពាក់ព័ន្ធ ដើម្បីបញ្ចៀសការងារច្រំដែល។ នៅក្នុងលេខបន្ទាប់ លោកអ្នកនឹងបានស្វែងយល់អំពីជំហានផ្សេងៗដែលត្រូវប្រើប្រាស់ ដើម្បីលើកកម្ពស់កិច្ចសន្ទនាគោលនយោបាយ និងកិច្ចសហការរវាងរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍន៍។

# ឯកសារបោះពុម្ពផ្សាយនាពេលខាងមុខ

## គោលការណ៍ណែនាំវិធីបន្សាំការប្រែប្រួលអាកាសធាតុទៅក្នុងវិស័យកសិកម្ម ធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធបៃតង

គោលការណ៍ណែនាំអំពីវិធីសាស្ត្របន្សាំ គឺជាបណ្ដុំឧបករណ៍អនុវត្តសម្រាប់អ្នកធ្វើការសម្រេចចិត្តអំពីរបៀបក្នុងការបញ្ជ្រាបភាពធន់នៃការប្រែប្រួលអាកាសធាតុទៅក្នុង វិស័យជាក់លាក់ផ្សេងៗ រួមមាន កសិកម្ម ធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធបៃតង។ គោលការណ៍ណែនាំនេះត្រូវបានបង្កើតឡើងក្រោមគាំទ្រពីគម្រោង "ការបញ្ជ្រាបភាពធន់នឹងការប្រែប្រួលអាកាសធាតុទៅក្នុងការធ្វើផែនការអភិវឌ្ឍន៍ (MCRDP)"។ តាមរយៈ ការប្រឹក្សាយោបល់ ជាមួយក្រសួងពាក់ព័ន្ធ រួមមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ ក្រ សួង សាធារណៈការ និងដឹកជញ្ជូន ឯកសារនេះនឹងបោះពុម្ពផ្សាយនៅក្នុងខែកញ្ញា ឆ្នាំ២០១៧ ទាំងជាភាសាអង់គ្លេស និងភាសាខ្មែរ។

# ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខ

- សីហា៖ សិក្ខាសាលាបណ្ដុះបណ្ដាលស្ដីពីការប្រែប្រួលអាកាសធាតុដល់យុវជនខេត្តកោះកុង។
- សីហា៖ សិក្ខាសាលាបណ្ដុះបណ្ដាលជាន់ខ្ពស់ស្ដីពីការបំពេញមាត្រដ្ឋានការប្រែប្រួលអាកាសធាតុដោយប្រើGIS ។
- សីហា៖ សន្និសីទថ្នាក់តំបន់ស្ដីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយតាមបែបសហគមន៍។
- កញ្ញា៖ សិក្ខាសាលាបណ្ដុះបណ្ដាលស្ដីពីការប្រែប្រួលអាកាសធាតុទៅកាន់និស្សិតនៃសកលវិទ្យាល័យដៃគូ។
- កញ្ញា៖ កិច្ចប្រជុំលើកទី២នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

*សម្រាប់ព័ត៌មានទាក់ទងនឹងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឬឯកសារបោះពុម្ពថ្មីៗ សូមតាមដានគេហទំព័រ www.camclimate.org.kh*

**គាំទ្រដោយ**

កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា
CAMBODIA CLIMATE CHANGE ALLIANCE
Implemented by: Ministry of Environment
Supported by: European Union, UNDP (Empowered lives. Resilient nations.), SWEDEN

**ទំនាក់ទំនង**

នាយកដ្ឋានប្រែប្រួលអាកាសធាតុ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
ស្ថិតក្នុងក្រសួងបរិស្ថាន អគារមរតកតេជោ ដីឡូត៍លេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ៖ +៨៥៥ ២៣ ៦៤០ ៣៨៣៣ | សារអេឡិចត្រូនិច៖ admin@camclimate.org.kh
គេហទំព័រ៖ www.camclimate.org.kh